ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.............................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១១ និងទិសដៅការងារឆ្នាំ២០១២ របស់ធនាគារជាតិនៃកម្ពុជា
## ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១២ នៅធនាគារជាតិនៃកម្ពុជា

**សូមគោរព :**

- **គណៈអធិបតី**
- **លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីស្នេហា**

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអតិបរមា ដោយបានមកចូលរួមក្នុងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១១ និងទិសដៅការងារឆ្នាំ២០១២ របស់ធនាគារជាតិនៃកម្ពុជា ជាមួយលោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញា នាពេលនេះ ។ ពិធីនេះត្រូវបានប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំ ដើម្បីផ្សព្វផ្សាយនិងអបអរសាទរចំពោះលទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាយើងសម្រេចបាន និងដើម្បីបង្កបរិយាកាសឱ្យមន្ត្រីបុគ្គលិករបស់យើង ទាំងនៅទីស្នាក់ការកណ្តាលនិងនៅសាខារាជធានី-ខេត្ត បានជួបប្រាស្រ័យទាក់ទងគ្នាជាបណ្តាញការងារ និងរាប់អានគ្នាកាន់តែជិតស្និទ្ធថែមទៀត ។

ទន្ទឹមពេលនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរយ៉ាងខ្លាំងចំពោះមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ទាំងអស់ ដែលបានខិតខំបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវ សម្រេចបានសមិទ្ធផលជាច្រើនជូនធនាគារជាតិនៃកម្ពុជា និងរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារឱ្យមានការរីកចម្រើនជាលំដាប់ ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែងរបស់រាជរដ្ឋាភិបាល ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបថា សន្និបាតរបស់យើងថ្ងៃនេះរៀបចំឡើងក្នុងគោលបំណងដើម្បីជម្រាបជូន ៖ ទី១/- សភាពការណ៍ទូទៅនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងកម្ពុជា និង ទី២/- លទ្ធផលការងារប្រចាំឆ្នាំ២០១១ របស់ធនាគារជាតិនៃកម្ពុជា ដូចខាងក្រោម ៖


ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

## I/- សភាពការណ៍ទូទៅនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងកម្ពុជា

នៅក្នុងឆ្នាំ២០១១ សេដ្ឋកិច្ចពិភពលោកមានអត្រាកំណើនទាបជាងឆ្នាំ២០១០ ដោយសារបញ្ហាប្រឈម បណ្តាលមកពីបញ្ហាអតុល្យភាពហិរញ្ញវត្ថុពិភពលោក វិបត្តិបំណុលសាធារណៈនៅតំបន់អឺរ៉ុបធ្ងន់ធ្ងរ ខណៈដែលប្រទេសអភិវឌ្ឍន៍ ជាពិសេស សហរដ្ឋអាមេរិក នៅមានអត្រានិកម្មភាពខ្ពស់ ជំនឿទុកចិត្តរបស់វិនិយោគិននិងអ្នកប្រើប្រាស់នៅទាប និងនៅបណ្តាប្រទេសជាច្រើន ការស្តារឡើងវិញពីគ្រោះធម្មជាតិពុំទាន់បានបញ្ចប់ជាស្ថាពរ ។ បញ្ហាទាំងនេះបានក្លាយជាបញ្ហាប្រឈមចំពោះទស្សនវិស័យសំខាន់នៃសេដ្ឋកិច្ចពិភពលោក ។

តាមការប៉ាន់ស្មានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) នៅដើមឆ្នាំ២០១២ បានបង្ហាញថា កំណើនសេដ្ឋកិច្ចពិភពលោកបានថយចុះពី ៥,២% នៅឆ្នាំ២០១០ មក ៣,៨% នៅឆ្នាំ២០១១ ក្នុងនោះសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍ ដូចជា សហរដ្ឋអាមេរិកមានអត្រាកំណើន ១,៨% និងអឺរ៉ុប ១,៦% ។ ទន្ទឹមនេះ គួរកត់សម្គាល់ថា ខណៈដែលសេដ្ឋកិច្ចតំបន់អាស៊ីមានមូលដ្ឋានរឹងមាំនិងបានរួមចំណែកគាំទ្រដល់កំណើនសេដ្ឋកិច្ចពិភពលោក ដោយប្រទេសចិនមានអត្រាកំណើន ៩,២% ឥណ្ឌា ៧,៤% និង អាស៊ានធំប្រាំ ៤,៨% ទោះបីសេដ្ឋកិច្ចជប៉ុនមានកំណើន -០,៩% ក៏ដោយ ។

នៅឆ្នាំ២០១១ សេដ្ឋកិច្ចកម្ពុជាបានបង្ហាញលទ្ធផលល្អគួរកត់សម្គាល់ ដោយស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរក្សាស្ថិរភាពយ៉ាងល្អប្រសើរ ទោះបីជាមានផលប៉ះពាល់ពីគ្រោះទឹកជំនន់នៅតំបន់ខ្លះក្តី ។ ស្ថិតក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រង និងការអនុវត្តនយោបាយសារពើពន្ធនិងរូបិយវត្ថុសមស្របរបស់រាជរដ្ឋាភិបាល សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករណ៍ថា នឹងមានកំណើនប្រមាណ ៦,៩% ដែលជាពិសេស ទ្រទ្រង់ដោយការរីកចម្រើននៃវិស័យកសិកម្ម ១,៤% ឧស្សាហកម្ម ១៤,១% ហើយដែលក្នុងនោះវិស័យកាត់ដេរ ២១% និងសេវាកម្ម ៥% ។

ប្រតិបត្តិការជញ្ជីងទូទាត់របស់ប្រទេសកម្ពុជាមានស្ថានភាពប្រសើរជាងឆ្នាំមុន ដែលឆ្លុះបញ្ចាំង តាមរយៈការថយចុះនៃឱនភាពសមតុល្យគណនីចរន្ត *(មិនរាប់បញ្ចូលបង្វែរផ្ទេរការ)* ពី ១០% មក ៨% នៃផសស ខណៈដែលសមតុល្យរួមមានអតិរេក ១,៧% នៃផសស ។ ទុនបម្រុងអន្តរជាតិដុលបានកើនឡើងដល់ជាង ៣ ពាន់លានដុល្លារអាមេរិក ដែលអាចធានាការនាំចូលបាន ៤,៩ ខែ ។ ធនាគារជាតិនៃកម្ពុជាបានបន្តគ្រប់គ្រងទុនបម្រុងអន្តរជាតិ ដោយប្រុងប្រយ័ត្ន ផ្អែកលើគោលការណ៍ : ទី១/- សុវត្ថិភាព ទី២/- សន្ទនីយភាព និង ទី៣/- ចំណូល ។ ការកើនឡើងនៃទុនបម្រុងអន្តរជាតិរបស់ប្រទេសនេះ ឆ្លុះបញ្ចាំងពីភាពរឹងមាំនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចជាតិ ។

## II/- លទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាសម្រេចបាននៅឆ្នាំ២០១១កន្លងមក

ក្នុងនាមជាអាជ្ញាធររូបិយវត្ថុ និងជាអាជ្ញាធរអាជ្ញាធរត្រួតពិនិត្យលើប្រព័ន្ធធនាគារនៅកម្ពុជា ធនាគារជាតិនៃកម្ពុជាបានខិតខំសម្រេចឱ្យបាននូវស្ថិរភាពថ្លៃ តាមរយៈការអនុវត្តគោលនយោបាយរូបិយវត្ថុប្រុងប្រយ័ត្ន សំដៅរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងទ្រទ្រង់ស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ ។ ក្នុងឆ្នាំ២០១១ អត្រាអតិផរណាបានប្រែប្រួលក្នុងអត្រាមធ្យមប្រចាំឆ្នាំត្រឹម ៥,៥% ដែលជាកម្រិតមួយអាចគ្រប់គ្រងបាន។ ប្រាក់រៀលបានឡើងថ្លៃ ៣,១% ធៀបនឹងឆ្នាំមុន ដោយសារការកើនឡើងនៃតម្រូវការប្រាក់រៀលក្នុងសកម្មភាពសេដ្ឋកិច្ច ។ វិនិយោគផ្ទាល់បរទេសត្រូវបានប៉ាន់ស្មានថា មានទំហំប្រមាណ ៦៧៧ លានដុល្លារអាមេរិក ។

ជារួម ក្នុងអំឡុងមួយទសវត្សរ៍នេះ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកមានស្ថិរភាពល្អប្រសើរ ដែលបានរួមចំណែកពង្រឹងជំនឿទុកចិត្តរបស់សាធារណជនមកលើរូបិយវត្ថុជាតិ ប្រព័ន្ធធនាគារ និងសេដ្ឋកិច្ចជាតិ ។ ការផ្គត់ផ្គង់រូបិយវត្ថុទូទៅ (M2) ក៏បានកើនឡើង ២១,៥% ធៀបនឹងឆ្នាំ២០១០ ។ ការកើនឡើងនៃរូបិយវត្ថុនេះ បានជួយជំរុញឱ្យមានកំណើនសេដ្ឋកិច្ច តាមរយៈការបង្កើនឥណទានចំពោះវិស័យសំខាន់ៗ មួយចំនួន ដូចជាវិស័យកសិកម្ម ឧស្សាហកម្ម និងសំណង់ ។

ក្រៅពីការចូលរួមពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាបានរួមចំណែកអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែងរបស់រាជរដ្ឋាភិបាល ហើយសម្រេចបានលទ្ធផលល្អប្រសើរដូចខាងក្រោម ៖

**១/- ការពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងនិងប្រតិបត្តិការធនាគារកណ្តាល** : ដោយឃើញពីការវិវត្តរីកចម្រើននៃវិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជាជាប់ជាប្រចាំ ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាបានសម្រេចធ្វើកំណែទម្រង់រចនាសម្ព័ន្ធគ្រប់គ្រងធនាគារជាតិនៃកម្ពុជា ដើម្បីពង្រឹងប្រតិបត្តិការធនាគារកណ្តាល ដោយបានកែសម្រួលប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា បង្កើតឱ្យមានអគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យ និងនាយកដ្ឋានផ្សេងៗទៀត ដើម្បីបែងចែកមុខងារ-ភារកិច្ចជាលក្ខណៈបច្ចេកទេសឱ្យច្បាស់លាស់ តួនាទីអ្នកត្រួតពិនិត្យ បញ្ញត្តិករ និងអ្នកគ្រប់គ្រងគោលនយោបាយរូបិយវត្ថុ ស្របតាមការអនុវត្តជាអន្តរជាតិ និងការវិវត្តរីកចម្រើននៃសេដ្ឋកិច្ចជាតិនាពេលបច្ចុប្បន្ន ។

**២/- ការរីកចម្រើននៃវិស័យធនាគារ** : បច្ចុប្បន្ន វិស័យធនាគារនៅកម្ពុជាកាន់តែមានភាពរឹងមាំ មានសុវត្ថិភាព និងមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ទាំងវិសាលភាពនិងទំហំប្រតិបត្តិការ ។ វិស័យនេះបានដើរតួនាទីស្នូលក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ ជាក់ស្តែងនៅឆ្នាំ២០១១ កន្លងមក មានធនាគារខ្នាតអន្តរជាតិចំនួន៣ បានមកបើកសាខារបស់ខ្លួននៅកម្ពុជា គឺធនាគារ ICBC, ធនាគារ Mega International Commercial Bank របស់ចិនតៃវ៉ាន់ និងធនាគាររបស់វៀតណាម MB ។ ផ្នែកវិសាលភាព បច្ចុប្បន្ននៅប្រទេស

កម្ពុជាយើងមានធនាគារពាណិជ្ជមានចំនួន ៣១ ធនាគារឯកទេសចំនួន ៧ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណចំនួន ៣២ ក្នុងនោះមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានសិទ្ធិទទួលប្រាក់បញ្ញើចំនួន ៧ ។ សូចនាករនេះបានបង្ហាញពីការកើនឡើងនៃជំនឿទុកចិត្ត និងការគាំទ្ររបស់វិនិយោគិនបរទេសមកលើទីផ្សារធនាគារ និងគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ។

ចំពោះទំហំប្រតិបត្តិការវិញ ប្រាក់បញ្ញើក្នុងប្រព័ន្ធធនាគារបានកើនឡើងចំនួន ២០,៤% និងឥណទានដល់វិស័យឯកជនបានកើនឡើងចំនួន ៣៣,៥% ធៀបនឹងគ្រាដូចគ្នានៅឆ្នាំ២០១០ ។ វិស័យដែលមានកំណើនឥណទានខ្ពស់ គឺវិស័យកសិកម្ម ឧស្សាហកម្ម សំណង់ និងពាណិជ្ជកម្ម ។ អ្នកផ្ញើប្រាក់មានចំនួន ១.២៦៦.៨១២ នាក់ និងអ្នកខ្ចីឥណទានមានចំនួន ២៩៤.៥៣៣ នាក់ ។ គិតត្រឹមឆ្នាំ២០១១ តាមរយៈអន្តរការិយកម្មធនាគារ វិនិយោគិនទទួលបានឥណទានប្រមាណ ៤.០៧២ លានដុល្លារអាមេរិក ។ តួលេខនេះធៀបនឹងឆ្នាំ២០១០ មានកំណើនចំនួន ៣៣,៥% ។ ការវិវត្តរីកចម្រើននេះ គួបផ្សំនឹងការអនុវត្តវិធានការប្រុងប្រយ័ត្នផងនោះ បានធ្វើឱ្យឥណទានមិនដំណើរការថយចុះជាបន្តបន្ទាប់ មកត្រឹម ២,៤៣% នៃកញ្ចប់ឥណទានសរុប ។

**៣/- វិស័យមីក្រូហិរញ្ញវត្ថុ** : មានការរីកចម្រើនយ៉ាងខ្លាំង និងមានហេដ្ឋារចនាសម្ព័ន្ធរឹងមាំដល់ជនបទ ។ វិស័យនេះត្រូវបានគេចាត់ទុកថា ជាវិស័យគន្លឹះក្នុងការរួមចំណែកលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជានៅជនបទ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា ។ ឥណទាននៃវិស័យមីក្រូហិរញ្ញវត្ថុបានកើនឡើងគួរឱ្យកត់សម្គាល់ ដោយចំនួនអតិថិជនបានកើនឡើងដល់ ១.១៤១.៩១៣ នាក់ និងឥណទានសរុបមានចំនួន ២៥៩១,២៦ ពាន់លានរៀល គឺកើនឡើងប្រមាណ ៤៦% ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០១០ ។ ប្រាក់បញ្ញើមានចំនួន ៤៥៩,៤៧ ពាន់លានរៀល ពីអ្នកផ្ញើប្រាក់ចំនួន ២៤២.១១៦ នាក់ ។ អនុបាតឥណទានមិនដំណើរការមានចំនួនតែ ០,២២% ប៉ុណ្ណោះ គិតត្រឹមដំណាច់ឆ្នាំ២០១១នេះ ។

ការរីកចម្រើននេះបានរួមចំណែកអភិវឌ្ឍអាជីវកម្មធុនតូចនិងមធ្យម និងវិស័យកសិកម្មនៅកម្ពុជា ។ វឌ្ឍនភាពនេះបានបញ្ជាក់ឱ្យឃើញថា ប្រជាពលរដ្ឋកម្ពុជាកាន់តែមានការយល់ដឹងពីសារៈសំខាន់នៃសេវាមីក្រូហិរញ្ញវត្ថុ និងស្គាល់ពីវប្បធម៌ឥណទានកាន់តែប្រសើរឡើង ។

**៤/- ការងារត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ** : ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ ដោយមានការចូលរួមពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា យើងបានចុះទៅត្រួតពិនិត្យដល់ទីកន្លែងនិងត្រួតពិនិត្យលើឯកសារ ដើម្បីជួយពង្រឹងអភិបាលកិច្ចល្អនិងភាពរឹងមាំរបស់គ្រឹះស្ថានធនាគារ ។ នៅឆ្នាំ២០១១ ធនាគារជាតិនៃកម្ពុជាបានបញ្ចប់ការត្រួតពិនិត្យដល់ទីកន្លែងចំពោះធនាគារពាណិជ្ជចំនួន២១ ធនាគារឯកទេសចំនួន៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានសិទ្ធិទទួលប្រាក់បញ្ញើចំនួន៧, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្សេងទៀតចំនួន៩, និងប្រតិបត្តិករឥណទានជនបទចំនួន ៥ ។

ចំពោះវិធានការត្រួតពិនិត្យដែលបច្ចុប្បន្នយើងបាននិងកំពុងអនុវត្ត គឺឈានពីការត្រួតពិនិត្យដោយផ្អែកលើមូលដ្ឋានច្បាប់ (Rule based) ឆ្ពោះទៅការត្រួតពិនិត្យដោយផ្អែកលើហានិភ័យ (Risk based) និងការត្រួតពិនិត្យផ្អែកលើទស្សនវិស័យអនាគត (Forward looking) សំដៅបន្តពង្រឹងសុវត្ថិភាពប្រព័ន្ធធនាគារទាំងមូល ។ អ្វីដែលគួរឱ្យកត់សម្គាល់នោះ គឺធនាគារជាតិនៃកម្ពុជាបានអនុវត្ត និងបញ្ចប់ដោយជោគជ័យនូវកម្មវិធីបង្កើនដើមទុនធនាគារ ពី ៥០ ពាន់លានរៀល ដល់ ១៥០ ពាន់លានរៀលចំពោះធនាគារពាណិជ្ជ និងពី ១០ ពាន់លានរៀល ដល់ ៣០ ពាន់លានរៀលចំពោះធនាគារឯកទេស ។

ជារួម ស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារមានភាពល្អប្រសើរ និងគោរពតាមវិធានការប្រុងប្រយ័ត្ន ។ ចំពោះគ្រឹះស្ថានធនាគារមួយចំនួនដែលមានចំណុចខ្វះខាត យើងបានផ្តល់អនុសាសន៍ដើម្បីកែតម្រូវ និងមានវិធានការដោះស្រាយតាមស្ថានភាពជាក់ស្តែងផងដែរ ។

**៥/- ការពង្រឹងអភិបាលកិច្ចល្អ** : សម្រាប់ប្រតិបត្តិការធនាគារជាតិនៃកម្ពុជា ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់ពង្រឹងការងារសវនកម្មផ្ទៃក្នុង និងការងារអធិការកិច្ចផ្ទៃក្នុងប្រតិបត្តិការរបស់ធនាគារជាតិយើង ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ។ យើងបានបំពាក់ប្រព័ន្ធព័ត៌មានវិទ្យា និងបានលើកកម្ពស់សមត្ថភាពត្រួតពិនិត្យផ្ទៃក្នុង សម្រាប់ស្នាក់ការកណ្តាល និងបណ្តាសាខាធនាគារជាតិនៃកម្ពុជា ឱ្យកាន់តែស៊ីជម្រៅថែមទៀត ។ នៅឆ្នាំ២០១១ មន្ត្រីជំនាញយើងបានចុះធ្វើសវនកម្មនៅសាខាធនាគារជាតិនៃកម្ពុជា ខេត្តស្វាយរៀង កំពង់ឆ្នាំង និងរាជធានីភ្នំពេញ និងបានផ្តល់អនុសាសន៍មួយចំនួនដើម្បីកែលម្អចំណុចខ្វះខាតទាំងនោះ ។

ចំពោះការងារអធិការកិច្ចវិញ យើងបានចុះឆ្មក់ត្រួតពិនិត្យដោយមិនជូនដំណឹងជាមុននៅសាខាធនាគារជាតិនៃកម្ពុជាបានចំនួន៧ ដោយផ្តោតទៅលើការងារគ្រប់គ្រងសុវត្ថិភាពឃ្លាំងប្រាក់ ការគ្រប់គ្រងសាច់ប្រាក់ និងបានផ្តល់អនុសាសន៍ណែនាំដើម្បីពង្រឹងគុណវុឌ្ឍិ វិន័យការងារមន្ត្រីបុគ្គលិក និងប្រសិទ្ធភាពការងារនៅតាមសាខាឱ្យកាន់តែប្រសើរ ។ ជាលទ្ធផល យើងពិនិត្យឃើញថា ប្រតិបត្តិការធនាគារជាតិនៃកម្ពុជាត្រូវបានពង្រឹង និងប្រព្រឹត្តទៅដោយរលូន និងមានលក្ខណៈល្អប្រសើរ ។

**៦/- ការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០** : ដោយយល់ឃើញពីសារៈសំខាន់នៃតួនាទីស្ថាប័នធនាគារនិងហិរញ្ញវត្ថុ ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ទើបកាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ រាជរដ្ឋាភិបាលបានអនុម័តលើឯកសារបច្ចុប្បន្នកម្មឯកសារ " យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ " ឱ្យទៅជា " យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ " ដើម្បីធ្វើជាផែនការរំកិល ឱ្យស្របតាម ១/- ការវិវត្តរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជា ក្រោមបរិយាកាសអំណោយផលនៃស្ថិរភាពនយោបាយ សន្តិភាព និងសន្តិសុខសង្គមក្នុងរយៈពេលមួយទសវត្សរ៍កន្លងមក ២/- ការប្រែប្រួលនៃស្ថាបត្យកម្មហិរញ្ញវត្ថុ

និងសេដ្ឋកិច្ចពិភពលោក បន្ទាប់ពីវិបត្តិសេដ្ឋកិច្ចពិភពលោកនាពេលថ្មីៗនេះ និង ៣/- តម្រូវការអភិក្រមអភិវឌ្ឍន៍ថ្មីដើម្បីគាំទ្រកំណើនសេដ្ឋកិច្ចរឹងមាំ និងអន្តរវិស័យរវាងផ្នែកនានានៃសេដ្ឋកិច្ចជាតិ ដែលក្នុងនោះវិស័យហិរញ្ញវត្ថុដើរតួនាទីគាំទ្រសំខាន់ជាប្រព័ន្ធ និងប្រទាក់ក្រឡាគ្នា ។ ឯកសារយុទ្ធសាស្ត្រនេះ មានលក្ខណៈជាផែនការរំកិល និងជាមាគ៌ាសម្រាប់អភិវឌ្ឍវិស័យហិរញ្ញវត្ថុឱ្យរឹងមាំ មានលក្ខណៈសមាហរណទាំងនៅក្នុងស្រុកនិងនៅក្នុងតំបន់ និងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

ក្នុងនាមជាលេខាធិការដ្ឋាននៃក្រុមការងារធ្វើបច្ចុប្បន្នកម្មឯកសារយុទ្ធសាស្ត្រនេះ ធនាគារជាតិនៃកម្ពុជាបានដើរតួនាទីជាអ្នកសម្របសម្រួលផង និងសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងយុត្តិធម៌ គណៈកម្មការមូលបត្រកម្ពុជា និងក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលផ្សេងទៀត ក្រោមជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។

**៧/- ការអភិវឌ្ឍទីផ្សារអន្តរធនាគារនិងរូបិយវត្ថុ** : ជាការងារអាទិភាពរបស់យើង ។ ក្នុងខណៈដែលទីផ្សារមូលបត្រនិងទីផ្សារទុននៅកម្ពុជាត្រូវបានបង្កើតឡើងក្នុងពេលថ្មីៗនេះ យើងបាន និងកំពុងបណ្តុះបណ្តាលមន្ត្រីជំនាញ និងផ្សព្វផ្សាយឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុយល់ដឹងពីសារៈសំខាន់ និងផលប្រយោជន៍នៃការប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុនេះ ធនាគារជាតិនៃកម្ពុជាបានរៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិមួយចំនួន ដើម្បីធ្វើមូលបត្រនីយកម្មប្រាក់បញ្ញើមានកាលកំណត់របស់គ្រឹះស្ថានធនាគារនៅធនាគារជាតិនៃកម្ពុជា ។

**៨/- ការពង្រឹងក្របខ័ណ្ឌច្បាប់និងការអភិវឌ្ឍប្រព័ន្ធជាតិទូទាត់សងប្រាក់** : បច្ចុប្បន្ន ដោយយល់ឃើញពីការរីកចម្រើននៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា និងដោយមានជំនួយឧបត្ថម្ភពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារជាតិនៃកម្ពុជាយើងកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់ជាតិ ដើម្បីសម្រួលដល់ការទូទាត់ឱ្យកាន់តែមានប្រសិទ្ធភាពក្នុងការទូទាត់ពាណិជ្ជកម្មថែមទៀត ។

ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអភិវឌ្ឍប្រព័ន្ធជាតិទូទាត់សងប្រាក់ ដោយបានបំពាក់ Hardware និងបានដំឡើងផ្នែក Software នៅក្នុងមជ្ឈមណ្ឌលរក្សាទុកទិន្នន័យ និងមជ្ឈមណ្ឌលសង្គ្រោះទិន្នន័យចប់សព្វគ្រប់ ព្រមទាំងរៀបចំសេចក្តីព្រាងច្បាប់ប្រព័ន្ធជាតិទូទាត់សងប្រាក់ ដើម្បីធ្វើជាមូលដ្ឋានគតិយុត្តិក្នុងការគ្រប់គ្រង និងត្រួតពិនិត្យប្រព័ន្ធទូទាត់នៅកម្ពុជា ។ យើងកំពុងបានបណ្តុះបណ្តាលមន្ត្រីជំនាញលើផ្នែកបែងចែកមុខងារ និងផ្នែកដំណើរការនៃប្រព័ន្ធនេះ ហើយសង្ឃឹមថា ប្រព័ន្ធនេះនឹងដំណើរការនៅឆ្នាំ២០១២ នេះ ។

**៩/- ការពង្រឹងការប្រើប្រាស់ប្រាក់រៀល** : ដុល្លារូបនីយកម្មនៅកម្ពុជាបាននាំមកនូវគុណសម្បត្តិផងនិងគុណវិបត្តិផង ប៉ុន្តែគុណវិបត្តិមានច្រើនជាងគុណសម្បត្តិចំពោះសេដ្ឋកិច្ចនិង

សង្គម ។ បញ្ហាដុល្លារូបនីយកម្មនៅកម្ពុជាមិនមែនកើតឡើងដោយសារការសម្រេចចិត្តរបស់រាជរដ្ឋាភិបាលទេ គឺដោយសារប្រវត្តិសាស្ត្របានបន្សល់ទុក ហើយបានក្លាយទៅជាបញ្ហារួមរបស់យើងទាំងអស់ បន្ទាប់ពីជំនឿទុកចិត្តរបស់សាធារណជនទូទៅមកលើប្រាក់រៀលបានធ្លាក់ចុះ ក្រោយរបបប្រល័យពូជសាសន៍ ប៉ុល ពត ។ បញ្ហានេះបានក្លាយទៅជាបញ្ហាប្រឈមចំពោះការអនុវត្តគោលនយោបាយរូបិយវត្ថុ ដែលតម្រូវឱ្យអាជ្ញាធរជាអ្នករៀបចំគោលនយោបាយនិងថ្នាក់ដឹកនាំស្ថាប័នហិរញ្ញវត្ថុ រៀបចំគោលនយោបាយនិងផែនការយុទ្ធសាស្ត្រច្បាស់លាស់និងប្រុងប្រយ័ត្ន ។

ក្នុងខណៈពេលដែលទីផ្សារមូលបត្រនិងទីផ្សារទុនត្រូវបានបង្កើតឡើង ដោយយល់ឃើញពីគុណវិបត្តិ និងគុណសម្បត្តិនៃដុល្លារូបនីយកម្មនៅក្នុងសេដ្ឋកិច្ច រាជរដ្ឋាភិបាលបានគាំទ្រនិងលើកកម្ពស់ឱ្យភ្នាក់ងារសេដ្ឋកិច្ចប្រើប្រាស់ប្រាក់រៀល ឱ្យកាន់តែទូលំទូលាយ សំដៅធ្វើបដិដុល្លារូបនីយកម្មពីសេដ្ឋកិច្ចជាតិ និងបានយកទៅចែងក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ របស់រាជរដ្ឋាភិបាល ។ នេះគឺជាបញ្ហារួមរបស់យើងទាំងអស់គ្នា ។ ដូច្នេះ យើងត្រូវរួមគ្នាដោះស្រាយបញ្ហានេះ ប្រកបដោយបុព្វហេតុនិងមនសិការជាតិ ។

**១០/- ការពង្រឹងប្រតិបត្តិការសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត** : ដើម្បីចូលរួមអនុវត្តតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលជំហានទី២ ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត យើងបានខិតខំពង្រឹងប្រតិបត្តិការផ្ទៃក្នុងរបស់ខ្លួន តាមរយៈការកែលម្អកន្លែងធ្វើការ បំពាក់ប្រព័ន្ធព័ត៌មានវិទ្យាដើម្បីឱ្យឆ្លើយតបតាមតម្រូវការ ការងារការបណ្តុះបណ្តាលផ្នែកការងារប្រតិបត្តិការនិងជំនាញ IT និងរៀបចំការងារចាត់តាំងមន្ត្រីបុគ្គលិកនៅតាមសាខារាជធានី-ខេត្ត ស្របតាមការងារជាក់ស្តែង ។

ទន្ទឹមពេលជាមួយគ្នា យើងបានដាក់ឱ្យអនុវត្តកម្មវិធីប្រព័ន្ធធនាគារស្នូល (CBS) និងការបណ្តុះបណ្តាលធនធានមនុស្ស ទាំងផ្នែកបច្ចេកទេសនិងការងារគ្រប់គ្រងយ៉ាងរឹងមាំ ដើម្បីឱ្យប្រតិបត្តិការរបស់យើងកាន់តែទូលំទូលាយ ស៊ីជម្រៅ និងមានព័ត៌មានត្រូវគ្នារវាងទីស្នាក់ការកណ្តាលនិងសាខារាជធានី-ខេត្ត ។ រហូតមកដល់ពេលនេះ ការងារនេះយើងបានអនុវត្តដោយរលូននិងមានប្រសិទ្ធភាព ។

**១១/- ការងារសមាគមមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា** : បច្ចុប្បន្ន មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ទាំងផ្នែកបរិមាណ និងទំហំមូលនិធិ ។ សមាគមនេះបានដើរតួនាទីយ៉ាងសំខាន់និងបម្រើផលប្រយោជន៍មន្ត្រីបុគ្គលិករបស់យើងយ៉ាងច្រើន ។ ការលំបាករបស់មន្ត្រីបុគ្គលិកយើងម្នាក់ៗតែងមានស្ថានភាព ទំហំ និងទម្រង់ខុសៗគ្នាដែរ សូមសមាគមពិនិត្យពីគោលការណ៍ជួយរួមចំណែកសម្រាលការលំបាករបស់មន្ត្រីបុគ្គលិករបស់យើង ទៅតាមស្ថានភាពជាក់ស្តែងបន្ថែមទៀត ។

### លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

ចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិជាលក្ខណៈទ្វេភាគីនិងពហុភាគីវិញ ធនាគារជាតិនៃកម្ពុជាមានកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងធនាគារកណ្តាលនៃប្រទេសក្នុងតំបន់ ហើយសម្រេចបានសមិទ្ធផល ដូចតទៅ ៖

**១/- មូលនិធិរូបិយវត្ថុអន្តរជាតិ** (IMF) : នៅឆ្នាំ២០១១ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានចាត់តាំងលោក Faisal Ahmed ធ្វើជាតំណាងរបស់ IMF ប្រចាំនៅប្រទេសកម្ពុជា និងចាត់លោក Arnaud de VILLEPOIX ទីប្រឹក្សាទូទៅរបស់ IMF ប្រចាំនៅធនាគារជាតិនៃកម្ពុជា ជំនួសលោក Thierry BANGRATZ ដែលបានបញ្ចប់អាណត្តិ ហើយវិលត្រឡប់ទៅបំពេញភារកិច្ចថ្មីនៅធនាគារកណ្តាលបារាំងវិញ ។ ក្រុមបេសកកម្ម IMF បានមកបំពេញបេសកកម្មនៅធនាគារជាតិនៃកម្ពុជាចំនួន៣លើក *ទី១)-* ពីថ្ងៃទី២១-២៨ ខែមីនា ឆ្នាំ២០១១ ដើម្បីវាយតម្លៃពីជំនួយបច្ចេកទេសដល់ធនាគារជាតិនៃកម្ពុជា *ទី២)-* ពីថ្ងៃទី៥-១១ ខែឧសភា ឆ្នាំ២០១១ ដើម្បីពិនិត្យពីស្ថានភាពសេដ្ឋកិច្ច និងពិភាក្សាគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុកម្ពុជា និង *ទី៣)-* ពីថ្ងៃទី២៨ ខែ វិច្ឆិកា ដល់ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១១ ក្រុមបេសកកម្ម IMF មាត្រាទី IV បានអញ្ជើញមកដើម្បីពិភាក្សាអំពីការអភិវឌ្ឍរីកចម្រើននៃសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា បញ្ហាប្រឈម និងការអនុវត្តគោលនយោបាយសេដ្ឋកិច្ចឆ្នាំ២០១១ និងឆ្នាំ២០១២ របស់កម្ពុជា ។

ជារួម អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានវាយតម្លៃល្អ ប្រកបដោយសុទិដ្ឋិនិយមអំពីស្ថានភាពនិងទស្សនវិស័យសេដ្ឋកិច្ចកម្ពុជា ។ IMF ក៏បានកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ព្រមទាំងបានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលនានា ដែលកើតចេញពីការខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការរក្សាស្ថិរភាពហិរញ្ញវត្ថុ ។

**២/- ធនាគារអភិវឌ្ឍន៍អាស៊ី** (ADB) : បានកោតសរសើរចំពោះរាជរដ្ឋាភិបាល និយាយជារួម និងនិយាយដោយឡែក ចំពោះធនាគារជាតិនៃកម្ពុជាដែលបានដើរតួនាទីស្នូលក្នុងការអនុវត្តគម្រោងការងារនៅក្នុងអនុកម្មវិធីទី៤ ដោយរលូន និងជោគជ័យ ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ។ ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ជំនួយបច្ចេកទេស ដើម្បីធ្វើបច្ចុប្បន្នកម្មឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ និងអភិវឌ្ឍប្រព័ន្ធជាតិទូទាត់សងប្រាក់ និងផាត់ទាត់មូលប្បទានបត្រនិងឧបករណ៍ទូទាត់ផ្សេងៗទៀត ជាលក្ខណៈមជ្ឈការ ដើម្បីសម្រួលដល់ការទូទាត់ពាណិជ្ជកម្មឱ្យកាន់តែមានប្រសិទ្ធភាពនិងសុវត្ថិភាពស្របតាមការរីកចម្រើននៃវិស័យហិរញ្ញវត្ថុនិងសេដ្ឋកិច្ចជាតិ ។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាក៏បានសហការជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) កំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធជាតិទូទាត់សងប្រាក់ផងដែរ ។

**៣/- ក្រុមប្រទេសអាស៊ាន (ASEAN) :** ប្រតិភូធនាគារជាតិនៃកម្ពុជាបានចូលរួមជាប្រចាំក្នុងកិច្ចប្រជុំថ្នាក់នយោបាយ និងបច្ចេកទេសសំខាន់ៗរបស់អាស៊ាននិងអាស៊ានបូកបី ដែលពង្រឹងកិច្ចសហប្រតិបត្តិការតាមដានស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងតំបន់ អនុវត្តផែនទីមគ្គុទ្ទេសក៍នៃសមាហរណកម្មរូបិយវត្ថុ-ហិរញ្ញវត្ថុអាស៊ាន ពង្រឹងទីផ្សារសញ្ញាប័ណ្ណក្នុងតំបន់ និងអនុវត្តយុទ្ធសាស្ត្រសហគមន៍សេដ្ឋកិច្ចអាស៊ាន ។

នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១ ធនាគារជាតិនៃកម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំថ្នាក់ទេសាភិបាលរងនិងអនុរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ (ASEAN Deputies) លើកទី៤ នៅទីក្រុងភ្នំពេញ ក្នុងគោលបំណងដើម្បីជំរុញការធ្វើសមាហរណកម្មវិស័យហិរញ្ញវត្ថុនិងរូបិយវត្ថុអាស៊ានស្របតាមផែនការយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន (AEC) ឆ្នាំ២០១៥ ។

ក្រៅពីនេះ ក្រុមការងារបច្ចេកទេសរបស់ធនាគារជាតិនៃកម្ពុជាបានចូលរួមប្រជុំក្រុមការងារបច្ចេកទេសអាស៊ាន និងអាស៊ាន+៣ជាប់ជាប្រចាំ ដើម្បីត្រៀមលក្ខណៈរៀបចំកិច្ចប្រជុំថ្នាក់ទេសាភិបាលរង និងថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ាន នៅទីក្រុងភ្នំពេញ នៅចុងខែមីនា ឆ្នាំ២០១២ ខាងមុខនេះ ។

**៤/- មជ្ឈមណ្ឌល SEACEN :** យើងបានទទួលធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិនៃមជ្ឈមណ្ឌលស៊ាសិន (SEACEN-EXCO) លើកទី៩ កាលពីថ្ងៃទី១៩-២១ ខែមករា ឆ្នាំ២០១១ នៅរាជធានីភ្នំពេញ និងបានបញ្ជូនមន្ត្រីជំនាញជាបន្តបន្ទាប់ឱ្យចូលរួមសិក្ខាសាលាវគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំសំខាន់ៗនានា នៅក្នុងក្របខ័ណ្ឌសហប្រតិបត្តិការស៊ាសិន ។

កាលពីថ្ងៃទី២៤-២៦ ខែកុម្ភៈ ឆ្នាំ២០១១ ប្រតិភូធនាគារជាតិនៃកម្ពុជាបានទៅចូលរួមកិច្ចប្រជុំថ្នាក់ទេសាភិបាល SEACEN លើកទី៤៦ នៅទីក្រុងកូឡុំបូ ប្រទេសស្រីលង្កា ។ ក្នុងអាណត្តិដែលធនាគារជាតិនៃកម្ពុជា ជាប្រធានក្រុមប្រឹក្សាទេសាភិបាល SEACEN និងគណៈកម្មាធិការប្រតិបត្តិ SEACEN ធនាគារជាតិនៃកម្ពុជាបានសម្របសម្រួលឱ្យធនាគារកណ្តាលចិនប្រជាមានិត (PBC) បានចូលជាសមាជិកពេញសិទ្ធិទី១៧របស់ SEACEN បានដោយជោគជ័យ ។

កាលពីថ្ងៃទី១១-១៣ ខែមករា ឆ្នាំ២០១២ ប្រតិភូធនាគារជាតិនៃកម្ពុជាបានទៅចូលរួមកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិរបស់ស៊ាសិន (SEACEN EXCO) នៅទីក្រុងកូឡុំបូ ប្រទេសស្រីលង្កា ដើម្បីពិភាក្សាអំពីបញ្ហាប្រឈមក្នុងការដឹកនាំធនាគារកណ្តាល និងការអនុវត្តគោលនយោបាយរូបិយវត្ថុក្រោយវិបត្តិ ។

នៅពេលឆាប់ៗខាងមុខនេះ មជ្ឈមណ្ឌល SEACEN នឹងមានធនាគារកណ្តាលឡាវ និងឥណ្ឌា ចូលជាសមាជិកទី១៨ និងទី១៩ របស់មជ្ឈមណ្ឌល SEACEN ថ្មីបន្ថែមទៀត ។

**៥/- កិច្ចប្រជុំធនាគារកណ្តាលនៃក្រុមប្រទេសនិយាយភាសាបារាំង (Francophone)** : ប្រតិភូធនាគារជាតិនៃកម្ពុជាតែងតែបានទៅចូលរួមកិច្ចប្រជុំប្រចាំឆ្នាំរបស់ធនាគារកណ្តាលនៃក្រុមប្រទេសនិយាយភាសាបារាំង (Francophone) ជារៀងរាល់ឆ្នាំ ។ កិច្ចប្រជុំនេះមានសារៈសំខាន់ណាស់សម្រាប់ធនាគារជាតិនៃកម្ពុជា ក៏ដូចជាប្រទេសជាតិយើង ព្រោះបានបង្ហាញពីកិច្ចសហប្រតិបត្តិការរបស់កម្ពុជា និងមុខមាត់កម្ពុជាក្នុងក្របខ័ណ្ឌតំបន់និងអន្តរជាតិ ។

កាលពីថ្ងៃទី១១-១៣ ខែឧសភា ឆ្នាំ២០១១ ធនាគារជាតិនៃកម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំ Francophone លើកទី១៨ នៅខេត្តសៀមរាប ដើម្បីពិភាក្សាអំពីតួនាទីធនាគារកណ្តាល បញ្ហាប្រឈម និងដំណោះស្រាយចំពោះវិបត្តិ ។ តាមរយៈកិច្ចប្រជុំនេះ ប្រទេសជាសមាជិក Francophone បានវាយតម្លៃខ្ពស់ពីការអភិវឌ្ឍរីកចម្រើនរបស់ប្រទេសកម្ពុជាលើគ្រប់វិស័យ ជាពិសេស ការរីកចម្រើននៃវិស័យធនាគារក្នុងរយៈពេល១២ឆ្នាំនៃដំណើរកម្ពុជាបន្ទាប់ពីមានសុខសន្តិភាព១០០% នៅទូទាំងប្រទេស នៅក្រោយឆ្នាំ១៩៩៩ មក ។

**៦/- កិច្ចសហប្រតិបត្តិការជាមួយក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក** : នៅឆ្នាំ២០១១ ក្នុងក្របខ័ណ្ឌនៃការងារសហប្រតិបត្តិការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម អង្គភាពស៊ើប-ការណ៍ហិរញ្ញវត្ថុកម្ពុជា (CAFIU) បានចូលរួមសហការយ៉ាងសកម្មជាមួយក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល និងសហគមអន្តរជាតិ ក្នុងការទប់ស្កាត់បទល្មើសនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ពាក់ព័ន្ធនឹងការប្រើប្រាស់ប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ដើម្បីសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ នៅឆ្នាំ២០១១ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាក៏បានចុះហត្ថលេខាលើឯកសារផ្លាស់ប្តូរព័ត៌មានជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុជប៉ុនផងដែរ ។

**៧/- កិច្ចសហប្រតិបត្តិការទ្វេភាគី** : យើងបានពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលថៃ កូរ៉េ បារាំង វៀតណាម ឡាវ ម៉ាឡេស៊ី លុចហ្សំបួរ អាល្លឺម៉ង់ និងធនាគារកណ្តាលនៃបណ្តាប្រទេសអាស៊ានមួយចំនួនទៀត ។ កាលពីថ្ងៃទី២៥-២៨ ខែឧសភា ឆ្នាំ២០១១ ប្រតិភូធនាគារជាតិនៃកម្ពុជាបានទៅចូលរួមប្រជុំទ្វេភាគី ជាមួយធនាគារកណ្តាលម៉ុងហ្គោលីក្នុងគោលបំណងដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងផ្លាស់ប្តូរបទពិសោធន៍ក្នុងវិស័យហិរញ្ញវត្ថុម៉ាក្រូសេដ្ឋកិច្ច និងការអភិវឌ្ឍធនធានមនុស្ស ។ ចាប់ពីថ្ងៃទី៩-១៣ ខែធ្នូ ឆ្នាំ២០១១ នៅទីក្រុងភ្នំពេញ ប្រតិភូធនាគារកណ្តាលឡាវបានចូលរួមកិច្ចប្រជុំទ្វេភាគីជាមួយធនាគារជាតិនៃកម្ពុជាដើម្បីផ្លាស់ប្តូរនិងបទពិសោធន៍ក្នុងការដឹកនាំធនាគារកណ្តាល និងការអនុវត្តគោលនយោបាយរូបិយវត្ថុក្រោយវិបត្តិសេដ្ឋកិច្ចសកលរវាងប្រទេសទាំងពីរ ។ ជារួម តាមរយៈកិច្ចសហប្រតិបត្តិការទ្វេភាគីនេះ ទំនាក់ទំនងរបស់ធនាគារជាតិនៃកម្ពុជាត្រូវបានពង្រឹង និងមានការវិវត្តរីកចម្រើនជាលំដាប់ ទាំងផ្នែកសហប្រតិបត្តិការមិត្តភាព ផ្នែកបច្ចេកទេស ការត្រួតពិនិត្យធនាគារឆ្លងដែន និងការផ្លាស់ប្តូរព័ត៌មានស្តីពីធនាគារនិងសេដ្ឋកិច្ច ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

សរុបមក សមិទ្ធផលទាំងឡាយដែលយើងមានសព្វថ្ងៃនេះ គឺកើតចេញពីការខិតខំប្រឹងប្រែងបំពេញការងារ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់របស់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ទាំងអស់ និងការចូលរួមសហការពីក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ។ ដើម្បីជ្រាបពីសមិទ្ធផលលម្អិតផ្សេងទៀត សូមអង្គសន្និបាតមេត្តាយកចិត្តទុកដាក់ស្តាប់បទឧទ្ទេសនាមរបស់ថ្នាក់ដឹកនាំរបស់យើង ដែលនឹងរាយការណ៍លម្អិតជូនអង្គសន្និបាតក្នុងពេលបន្តិចទៀតនេះ ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការ និងការខិតខំប្រឹងប្រែងរបស់សមាជិកក្រុមប្រឹក្សាភិបាលនិងមន្ត្រីបុគ្គលិកទាំងអស់ ដែលបានរួមចំណែកកសាងធនាគារជាតិនៃកម្ពុជាឱ្យទទួលបានលទ្ធផលល្អប្រសើរគួរជាទីមោទនៈ ។ ខ្ញុំនៅតែមានជំនឿជឿជាក់ថា លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា នៅតែបន្តស្មារតីសាមគ្គីគ្នាជាប្រពៃណីនេះតទៅទៀត ។ អង្គសន្និបាតរបស់យើងនឹងប្រព្រឹត្តទៅរយៈពេលពីរថ្ងៃ សូមលោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ខិតខំស្តាប់របាយការណ៍ស្តីពីលទ្ធផលការងារដែលអនុវត្តកន្លងមក និងលើកទិសដៅការងារសម្រាប់ឆ្នាំ២០១២ ដើម្បីយកទៅអនុវត្តការងាររបស់ខ្លួនឱ្យបានជោគជ័យនិងមានប្រសិទ្ធភាព ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់ លោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញា ដែលមានវត្តមាននៅក្នុងអង្គសន្និបាតនេះ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ហើយទន្ទឹមនឹងនេះ សូមឱ្យអង្គសន្និបាតរបស់យើងមានដំណើរការប្រកបដោយជោគជ័យ ។

**ខ្ញុំសូមប្រកាសបើកអង្គសន្និបាតជាផ្លូវការចាប់ពីពេលនេះតទៅ ។**

**សូមអរគុណ!**